ព័ត៌មានជាតិ

# ពិព័រណ៍គំនូរសិល្បៈចំនួន១៣៩ផ្ទាំង ត្រូវបានតាំងបង្ហាញនៅវិចិត្រសាលរបស់អង្គការហ្វាពន្លឺសិល្បៈបាត់ដំបង ដើម្បីលើកកម្ពស់វិស័យសិល្បៈគំនូររបស់ជាតិ

១៤-តុលា-២០២៤ ០៣:៣៤ ល្ងាច 1437 Share



បាត់ដំបង ៖ ពិព័រណ៍គំនូរសិល្បៈចំនួន១៣៩ផ្ទាំង ត្រូវបានដាក់តាំងនៅវិចិត្រសាលរបស់សមាគមហ្វាពន្លឺសិល្បៈបាត់ដំបង ដើម្បីបង្ហាញដល់សាធារណៈជន និងភ្ញៀវទេសចរជាតិ អន្តរជាតិ បានចូលរួមទស្សនាអំពីស្នាដៃសិស្សសិល្បៈ និងផ្តល់ការលើកទឹកចិត្តបន្ថែម ក្នុងការលើកកម្ពស់តម្លៃនៃការខិតខំប្រឹងប្រែងរបស់សិស្សសិល្បៈនៃសមាគមហ្វាពន្លឺសិល្បៈបាត់ដំបង ។

គោលបំណងសំខាន់ក្នុងការបើកពិព័រណ៍ស្នាដៃសិល្ប នាពេលនេះ គឺចង់បង្ហាញស្នាដៃសិល្បៈ ដែលជាលទ្ធផលនៃកម្មសិក្សារបស់សិស្សសិល្បករ សិល្បការិនី និងគ្រូ ទៅកាន់តំបន់រមណីយដ្ឋានប្រវត្តិសាស្រ្ត និងទីតាំងបេតិកភណ្ឌនានា ក្នុងខេត្តកំពង់ធំ សៀមរាប និងខេត្តកំពត ដែលជាផ្នែកមួយនៃកម្មវិធីសិក្សារបស់សាលាជំនាញសិល្បៈសូនរូប នៃសមាគមហ្វារពន្លឺសិល្បៈ ព្រមទាំងចង់បង្ហាញអំពីគុណភាពនៃការសិក្សានៅសាលាជំនាញសិល្បៈសូនរូបផងដែរ ។

នាយកអង្គការហ្វាពន្លឺសិល្បៈ បានបញ្ជាក់ថា ប្រធានបទសម្រាប់ស្នាដៃពិព័រណ៍គំនូរនាពេលនេះ គឺការចាប់យកចំណុចសំខាន់ដ៏ល្អឯករបស់

កម្ពុជា តាំងពីសម័យអង្គរ និងសម័យអាណានិគមថ្មីៗនេះ ។ ស្នាដៃទាំងនេះបង្កប់នូវអារម្មណ៍អាឡោះអាល័យ និងរំលេចនូវភាពសំខាន់នៃការរក្សាប្រវត្តិសាស្ត្ររបស់ជាតិកម្ពុជា ។ ស្នាដៃសិល្បៈ ចាប់យកទម្រង់មួយផ្សេងទៀតរបស់សិល្បៈ ស្ថាបត្យកម្ម និងការងាររបស់ជាងសំណង់ដែលពោរពេញដោយការស្រឡាញ់ និងមានជំនាញខ្ពស់ជាច្រើន ដែលបានសាងសង់អគារដោយយកចិត្តទុកដាក់ពិតប្រាកដចំពោះព័ត៌មានលម្អិត ទិដ្ឋភាព និងសមាមាត្រជាអ្វីដែលសូម្បីតែអគារទូទៅបច្ចុប្បន្ននេះអាចច្រណែនបាន ។ គួរឲ្យស្ដាយយើងកម្របានឃើញនូវសិល្បៈដ៏វិចិត្របែបនេះ នៅក្នុងសំណង់សព្វថ្ងៃណាស់ ។

នាយកសាលាសិល្បៈសូនរូប នៅសមាគមហ្វាពន្លឺសិល្បៈបាត់ដំបង លោក តោ វុត្ថា បានបញ្ជាក់ថា ការដាក់តាំងពិព័រណ៍សិល្បៈគំនូរ គឺតែងតែទទួលបាននូវភាពជោគជ័យ ដោយសារតែបានបង្ហាញនូវស្នាដៃរបស់សិស្ស ដើម្បីឱ្យគេបានមើលឃើញ និងភ្ញៀវមានការចាប់អារម្មណ៍ដែលស្នាដៃទាំងនេះ បានធ្វើការផ្លាស់ប្តូរពីវិចិត្រសាលរបស់អង្គការហ្វាពន្លឺសិល្បៈខេត្តបាត់ដំបង ទៅរាជធានីភ្នំពេញ និងវិចិត្រសាលផ្សេងៗជាដៃគូផងដែរ ។

ជាសិស្សផ្នែកគំនូរជីវចល នៃសាលាសិល្បៈសូនរូប នៅសមាគមហ្វាពន្លឺសិល្បៈបាត់ដំបង ប្អូនស្រី លីម ស្រីនាថ បានរំលេចថា នៅក្នុងពេលរៀន និងពេលចុះកម្មសិក្សា គឺទទួលបានបទពិសោធន៍ច្រើនទាក់ទងជាមួយសិល្បៈគំនូរ និងការប្រាស្រ័យទាក់ទងអ្នកនៅជុំវិញខ្លួន និងការធ្វើការងារជាមួយនឹងក្រុមហ៊ុននៅផ្នែកខាងក្រៅ ដោយសារតែសាលាបានផ្ដល់ឱកាសឱ្យសិក្សាស្រាវជ្រាវអំពីការរៀនទាំងផ្នែកគំនូរ និងផ្នែកគំនូរជីវចល ។

អភិបាលរងក្រុងបាត់ដំបង លោក រុន សុខគ្រី បានចាត់ទុកថា ស្នាដៃនេះគឺពិតជាមានលក្ខណៈពិសេសគួរកត់សម្គាល់ជាច្រើនក្នុងសកម្មភាពរស់រវើកនាសម័យនីមួយៗ ដែលស្នាដៃនេះបានបង្ហាញពីទិដ្ឋភាពនៃការរស់នៅនាសម័យអង្គរដ៏រុងរឿង និងសម័យក្រោយអាណានិគម ធ្វើឱ្យអារម្មណ៍អ្នកទស្សនា ដូចបានត្រឡប់ទៅដល់ទិដ្ឋភាពពីមុនដោយផ្ទាល់ដូច្នេះដែរ ។

គួរបញ្ជាក់ថា ពិព័រណ៍សិល្បៈនេះ គឺជាលទ្ធផលនៃកម្មសិក្សា ដែលបានរៀបចំសម្រាប់សិស្សានុសិស្ស នៃសាលាជំនាញសិល្បៈសូនរូប ហើយក៏មានការអញ្ជើញអតីតសិស្ស និងសិល្បៈកររបស់សមាគមហ្វាពន្លឺសិល្បៈ

បាត់ដំបង ចូលរួមចែករំលែកបទពិសោធន៍ល្អៗ ទៅកាន់សិស្សានុសិស្ស
ជំនាន់ក្រោយនេះផងដែរ ៕

ដោយ ៖ ឡាច សុគន្ធាវី




























PROMOTED CONTENT


Kate Was Caught Getting Angry On Camera

Buzz Day


Passenger Captures Cruise Ship Collision With Iceberg (Watch)

Buzz Day


Michelle Obama Finally Spilled The Beans On Her Marriage!

Buzz Day


The Real Reason These 9 Celebrities Don’t Have Kids

Brainberries


Celebs Mauled To Death By The Animals They Loved

Limelight Media


The 9 Secrets Every Couple Needs For A Happier Relationship

Herbeauty


Suri Cruise And Toby: The Inside Scoop On Her Rumored Romance

Herbeauty


What Happened In This Interview Will Leave You Speechless

Limelight Media


## ដើម្បីទទួលពត៌មានថ្មីៗ

| FACEBOOK | TELEGRAM | YOUTUBE | WEBSITE |
| --- | --- | --- | --- |

(HTTPS://WWW.YOUTUBE.COM/USER/CNCTVCAMBODIA)




(https://cnc.com.kh/)

---

(HTTPS://W[illegible]SSPORT.COM.KH)

ទំនាក់ទំនងព័ត៌មានទូទៅ 089 999 770 | ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 077 790 005

© រក្សាសិទ្ធិគ្រប់យ៉ាងដោយ CNC ឆ្នាំ 2024